# ព្រះរាជក្រម

នស/រកម/០៤០៦/០០៨

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមការកំណត់របស់មាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

## ស្តីពី

## វិសោធនកម្ម

## ច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

**មាត្រា មួយ.-**

មាត្រា ១ និងមាត្រា ២ នៃច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម :

**មាត្រា ១ .- ថ្មី**

យោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ត្រូវដាក់ឱ្យចូលនិវត្តន៍អាស្រ័យតាមលក្ខខណ្ឌដូចខាងក្រោម :

១-នាយទាហានចាប់ពីថ្នាក់វរសេនីយ៍ឯក និងវរនាវីឯកឡើងទៅ នៅពេលដល់អាយុ ៦០ (ហុកសិប) ឆ្នាំ

២-នាយទាហានថ្នាក់វរសេនីយ៍ទោ និងវរនាវីទោ នៅពេលដល់អាយុ ៥៨ (ហាសិបប្រាំបី) ឆ្នាំ

៣-នាយទាហានចាប់ពីថ្នាក់នាយចំណង់ និងនាយនាវីចំណង់ ដល់ថ្នាក់វរសេនីយ៍ត្រី និងវរនាវីត្រី នៅពេលដល់អាយុពី ៥៣ (ហាសិបបី) ឆ្នាំ ទៅ ៥៥ (ហាសិបប្រាំ) ឆ្នាំ ។

៤-នាយទាហានរងចាប់ពីថ្នាក់ពលបាលត្រី និងចក្របាលត្រី ដល់ថ្នាក់ព្រិន្ទបាលឯក និងនាយចក្របាលឯក នៅពេលដល់អាយុពី ៣៨ (សាមសិបប្រាំបី) ឆ្នាំ ទៅ ៤២ (សែសិបពីរ) ឆ្នាំ ។

នាយទាហានថ្នាក់ឧត្តមសេនីយ៍ ឧត្តមនាវី វីរជន និងវរសេនីយ៍ឯក កងទ័ពជើងអាកាស វរនាវីឯកកងទ័ពជើងទឹក ដែលមានគុណសម្បត្តិនិងសមត្ថភាព ឬជាអ្នកជំនាញឯកទេស ទោះបីដល់អាយុចូលនិវត្តន៍ក៏ដោយ តាមការស្នើសុំរបស់សាមីខ្លួន ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬតាមតម្រូវការចាំបាច់របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចត្រូវរក្សាទុកដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ប្រទេសជាតិ ។

យោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ អាចស្នើសុំចូលនិវត្តន៍មុនពេលកំណត់បាន ។

លក្ខខណ្ឌ និងបែបបទនៃការចូលនិវត្តន៍តាមការកំណត់និងការចូលនិវត្តន៍មុនពេលកំណត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ២ .- ថ្មី**

យោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទអាចទទួលរបបសោធននិវត្តន៍បាន ត្រូវមានលក្ខខណ្ឌដូចខាងក្រោម :

ក-របបសោធននិវត្តន៍អប្បបរមា

១-ចំពោះយោធិនអាជីព ដែលបានបំពេញការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពយ៉ាងតិច ១០ (ដប់) ឆ្នាំ ចំពោះបុរស និងយ៉ាងតិច ៨ (ប្រាំបី) ឆ្នាំ ចំពោះនារី ។

២-ចំពោះយោធិនអាជីពដែលបានបំពេញការងារមិនប៉ះពាល់ដល់សុខភាព ឬគ្រោះថ្នាក់ផ្សេងៗចំនួន ២០ (ម្ភៃ) ឆ្នាំ ចំពោះបុរស និងចំនួន ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះនារី ។

ខ-របបសោធននិវត្តន៍អតិបរមា

១-ចំពោះយោធិនអាជីព ដែលបានបំពេញការងារនៅតំបន់លំបាក ការ

ងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពយ៉ាងតិច ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបុរស និងយ៉ាងតិច ១២ (ដប់ពីរ) ឆ្នាំ ចំពោះនារី ។

២-ចំពោះយោធិនអាជីពដែលបានបំពេញការងារមិនប៉ះពាល់ដល់សុខភាព ឬគ្រោះថ្នាក់ផ្សេងៗលើសពី ២០ (ម្ភៃ) ឆ្នាំ ចំពោះបុរស និងលើសពី ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះនារី ។

៣-ចំពោះឧត្តមសេនីយ៍ ឧត្តមនាវី ឬវីរជនក្នុងកងយោធពលខេមរភូមិន្ទដែលបានបំពេញលក្ខខណ្ឌដូចមានចែងនៅចំណុច (ក) ខាងលើ ត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមា ។

៤-ចំពោះយោធិនពិការ ដែលនៅបំពេញការងារជាប់រហូតដល់អាយុចូលនិវត្តន៍ ។

ដោយឡែក លក្ខខណ្ឌ បែបបទស្តីពីរបបឧបត្ថម្ភចំពោះយោធិនពិការដែលបំពេញការងារមិនបាន យោធិនពលី មរណៈ បង្គូស្លាប់ និងបាត់ខ្លួនត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ពីរ.–**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៦

នស/រកម.០៤០៦.០៣៦ ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

ហត្ថលេខា

ទៀ បាញ់

លេខ ១៦១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

សៅ ឌី តាន់